00643961

E44

# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: មេធាវីការពារក្តីរបស់អ្នកស្រី អៀង ធីរិទ្ធ

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី១៤ ខែ កុម្ភៈ ឆ្នាំ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ **សាធារណៈ / Public**

ប្រភេទចំណាត់ថ្នាក់ឯកសារ

ការពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះ

អាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**អញ្ញត្រកម្មរបស់មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ**

---

**មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ៖**

លោក ផាត់ ពៅស៊ាង

កញ្ញា Diana ELLIS, QC

**ចៅក្រមអង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យូ មណី

ចៅក្រម Jean-Marc LA VERGNE

ចៅក្រម យ៉ា សុខន

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 14 / 02 / 2011
ម៉ោង (Time/Heure): 14 : 00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖</u>**

ពេជ អង្គ

Elisabeth SIMONNEAU FORT

**<u>សហព្រះរាជអាជ្ញា៖</u>**

លោកស្រី ជា លាង

លោក Andrew CAYLEY

# I. សេចក្តីផ្តើម

១. នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) បានចេញ "ដីកាដំណោះស្រាយ" [1] ដែលមេធាវីការពារក្តីលោកស្រី អៀង ធីរិទ្ធ (**ជនជាប់ចោទ**) បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានោះ (**បណ្តឹងឧទ្ធរណ៍**) [2] ។ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរួម (**ចម្លើយតបរួម**) [3] ហើយមេធាវីការពារក្តីបានដាក់ចម្លើយតប[4]។ នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានចេញ "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ" (**សាលដីការបស់ អ.ប.ជ**) [5] ដែលសាលដីកាមិនបានលើកឡើងពីសំអាងហេតុដែលបានគូសបញ្ជាក់សម្រាប់សេចក្តីសម្រេចនោះទេ ដែលសំអាងហេតុនោះ សាលដីកាបានប្រកាសថា "នឹងធ្វើឡើងតាមពេលវេលាកំណត់" [6] ។ ពុំមានសំអាងហេតុណាមួយត្រូវបានជូនដំណឹងដល់ភាគីនានានៅឡើយ។

---

[1] ក.ស.ច.ស ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារលេខ D427។

[2] បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារលេខ D427/2/1។

[3] ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ នួន ជា, អៀង សារី និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១០ ឯកសារលេខ D427/2/7។

[4] ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកា ដំណោះស្រាយ ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១០ ឯកសារលេខ D427/2/11។

[5] អ.ប.ជ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ ឯកសារលេខ D427/2/12។

[6] សាលដីការបស់ អ.ប.ជ ទំព័រ៥។

២. ដូចដែលបានវែកញែកពីពេលមុនៗ[7] មេធាវីការពារក្ដីបានលើកឡើងថា សាលដីការបស់ អ.ប.ជ មិនមានលក្ខណៈគ្រប់គ្រាន់ជា "សេចក្ដីសម្រេច" ដូចដែលបានកំណត់នៅក្នុងវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុង ដែលតម្រូវថាសេចក្ដីសម្រេចត្រូវមានបញ្ជាក់ហេតុផលនោះទេ។ លើកលែងតែ និងលុះត្រាតែសាលដីការបស់ អ.ប.ជ ត្រូវបានបញ្ជាក់ហេតុផល មិនដូច្នេះទេសាលដីកានោះនឹងមិនស្ថិតនៅក្នុងវង្វង់នៃវិធាន ៧៧(១៤) នៃវិធានផ្ទៃក្នុងឡើយ។ នៅក្នុងកាលៈទេសៈនេះ មេធាវីការពារក្ដីស្នើសុំសិទ្ធិក្នុងការដាក់សេចក្ដីសន្និដ្ឋានបន្ថែមដាច់ដោយឡែកពីគ្នា នៅពេលណាដែលសំអាងហេតុដែលបានគូសបញ្ជាក់សម្រាប់សាលដីការបស់ អ.ប.ជ ត្រូវបានជូនដំណឹងដល់ភាគីនានា។ វាមិនអាចទៅរួចទេ ក្នុងការវិភាគអំពីសាលដីកា របស់ អ.ប.ជ នៅដំណាក់កាលនេះ។ ហេតុនេះ ហើយការវិភាគនេះនឹងត្រូវបានកំណត់ជាសំខាន់តែទៅលើដីកាដំណោះស្រាយ របស់ ក.ស.ច.សប៉ុណ្ណោះ។

## ១.១ សវនាការបឋម

៣. មាត្រា ៥.១ នៃសេចក្ដីណែនាំអនុវត្តស្ដីពីការដាក់ឯកសារ អនុញ្ញាតឱ្យមេធាវីការពារក្ដីដាក់អញ្ញត្រកម្មរបស់ខ្លួនជាឯកសារដែលមានចំនួន ១៥ ទំព័រ។ នៅពេលដែលមេធាវីការពារក្ដីបានដាក់ "សំណើបន្ទាន់របស់មេធាវីការពារក្ដី អ្នកស្រី អៀង ធីរិទ្ធស្នើសុំឱ្យមានការបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់អញ្ញត្រកម្ម"[8] ការស្នើនេះមិនត្រូវបានសម្រេចមុនពេលធ្វើឯកសារនេះចប់ទេ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈអន្តរការិយាល័យ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១១ ដោយបង្ហាញថា សំណើសុំបន្ថែមចំនួនទំព័រ និងពេលវេលាមិនត្រូវបានអនុញ្ញាតនោះទេ។ ហេតុនេះហើយ មេធាវីការពារក្ដីដាក់ឯកសារដែលមានចំនួន ១៥ ទំព័រ នៅក្នុងរយៈពេលកំណត់ដែលបានលើកឡើងតាមរយៈ "ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ" របស់អង្គជំនុំជម្រះសាលាដំបូង[9]។ ឯកសារនេះនឹងសំដៅលើទឡ្ហីករណ៍ផ្នែកយុត្តាធិការ

---

[7] សូមមើលឧទាហរណ៍ សំណើបន្ទាន់របស់មេធាវីការពារក្ដីសុំកំណត់ថ្ងៃផុតកំណត់ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ ឯកសារលេខ D14 កថាខណ្ឌ ៤ដល់៥។

[8] សំណើបន្ទាន់របស់មេធាវីការពារក្ដី អៀង ធីរិទ្ធ សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់អញ្ញត្រកម្ម ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១១ ឯកសារលេខ E24។

[9] អ.ជ.ស.ជ ដីកាបង្គាប់ឱ្យដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ ឯកសារលេខ E9។

ដែលបានលើកឡើងកាលពីពេលមុនៗ ជាពិសេស បណ្តឹងឧទ្ធរណ៍ និងចម្លើយតប[10]។ ទឡ្ហីករណ៍នានាដែលត្រូវបានលើកឡើងនៅក្នុងឯកសារទាំងអស់នោះ ត្រូវបានបញ្ចូលគ្នាជាសំអាងតាមរយៈសេចក្តីយោង។

៤. មេធាវីការពារក្តីមានចេតនាបរិយាយអំពីបញ្ហានានា ដែលបានបង្ហាញនៅក្នុងសំណើសុំនេះឲ្យបានពិស្តារជាងនេះនៅក្នុងពេលសវនាការបឋម យោងតាមវិធាន ៨៩ស្ទួន (៣) នៃវិធានផ្ទៃក្នុង។

## ១.២ សំណើសុំចេញសេចក្តីសម្រេចលើអញ្ញត្រកម្មមុនពេលចាប់ផ្តើមសវនាការ

៥. មេធាវីការពារក្តីបានស្នើដោយក្តីគោរព សុំឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការសម្រេចលើបញ្ហាទាំងអស់នេះមុនពេលចាប់ផ្តើមសវនាការ និងមិនរង់ចាំរហូតដល់ពេលចេញសាលក្រមនោះទេ។ វិធាន ៨៩(៣) នៃវិធានផ្ទៃក្នុង អនុញ្ញាតឲ្យអង្គជំនុំជម្រះធ្វើការសម្រេចលើបញ្ហាទាំងអស់នេះភ្លាមៗឬនៅពេលដំណាលគ្នានឹងពេលចេញសាលក្រមសម្រេចលើអង្គសេចក្តី។ មេធាវីការពារក្តីស្នើ ដោយក្តីគោរព សុំឲ្យអង្គជំនុំជម្រះដោះស្រាយបញ្ហាទាំងអស់នេះនៅដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីនេះ ពីព្រោះជនជាប់ចោទមានសិទ្ធិទទួលបានការសម្រេចលើបញ្ហាទាំងអស់នេះមុនពេលខ្លួនត្រូវបានជំនុំជម្រះក្តី។ វាក៏នឹងរក្សាសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តី ដោយមិនពន្យារពេលយូរហួស ដូចដែលធានាដោយមាត្រា ១៤(៣)(គ) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ផងដែរ ពីព្រោះមាត្រានេះនឹងរារាំងការចោទប្រកាន់ អំពីបទឧក្រិដ្ឋនានា ឬអំពីទម្រង់នៃការទទួលខុសត្រូវទាំងឡាយណាដែលអាចស្ថិតនៅក្រៅវិសាលភាពនៃយុត្តាធិការរបស់ អ.វ.ត.ក។

៦. នៅក្នុងរឿងក្តី *Karemera* នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា (ICTR) អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើការសម្រេចអំពីការតតាំងផ្នែកយុត្តាធិការមុនពេលចាប់ផ្តើមសវនាការ ពីព្រោះជនជាប់ចោទមាន "សិទ្ធិមិនទទួលបាននូវការកាត់សេចក្តី និងមិនទទួលបាននូវការការពារប្រឆាំងនឹងការចោទប្រកាន់ដែលស្ថិតនៅ

[10] ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងចម្លើយតបរួមរបស់ព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១០ ឯកសារលេខ D427/2/11។

00643966



ក្រៅយុត្តាធិការរបស់តុលាការ" [11]។ ក៏ដូចគ្នាដែរ នៅក្នុងរឿងក្តី *Semanza* អង្គជំនុំជម្រះសាលាដំបូងរបស់ ICTR បានលើកឡើងថា អង្គជំនុំជម្រះត្រូវដោះស្រាយលើសំណើបឋមមុនពេលឈានទៅដំណើរការសវនាការ [12]។ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) បានលើកឡើងនៅក្នុងរឿងក្តី *Tadic* ថា ការតតាំងផ្នែកយុត្តាធិការលើកឡើងនូវបញ្ហាសំខាន់នៃភាពយុត្តិធម៌ និងថាគោលបំណងមួយក្នុងចំណោមគោលបំណងដែលបានគូសបញ្ជាក់អំពីការតតាំងនោះ គឺដើម្បីបង្កៀងលទ្ធភាពរបស់ជនជាប់ចោទមិនឱ្យទទួលបានការជំនុំជម្រះក្តី និងការផ្តន្ទាទោសអំពីបទចោទប្រកាន់នានា ដែលមិនត្រូវបានរៀបចំឱ្យបានត្រឹមត្រូវនៅចំពោះមុខតុលាការ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់ ICTY បានលើកឡើងថា "បញ្ហាសំខាន់ដូចជាយុត្តាធិការរបស់តុលាការអន្តរជាតិនេះ មិនត្រូវបានរក្សាទុកសម្រាប់ការសម្រេចសេចក្តីនៅចុងបញ្ចប់នៃសវនាការ ដែលអាចអូសបន្លាយរយៈពេលវែង ដែលអាចរំភើបចិត្ត និងដែលអាចមានការចំណាយច្រើនឡើយ" [13]។

៧. ដូចនេះ មេធាវីការពារក្តីស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការវិនិច្ឆ័យទៅលើអញ្ញត្រកម្មមុនពេលអនុញ្ញាតឱ្យរៀបចំការជំនុំជម្រះក្តីលើរឿងក្តីនេះ។

## II. បទបញ្ញត្តិច្បាប់ដែលពាក់ព័ន្ធ

៨. វិធាន ៨៩ នៃវិធានផ្ទៃក្នុង កំណត់អំពីវិសាលភាពសម្រាប់អញ្ញត្រកម្មដូចខាងក្រោម៖

១. អញ្ញត្រកម្មទាក់ទងទៅនឹង:

ក- យុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង

---

[11] រឿងក្តី *ព្រះរាជអាជ្ញា តទល់នឹង Karemara et al,* អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកាលើបណ្តឹងឧទ្ធរណ៍ស្តីពីយុត្តាធិការ: សហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៦ លេខសំណុំរឿង ICTR-98-44-AR72.5 & ICTR-98-44-AR72.6 កថាខណ្ឌ ២៣។

[12] រឿងក្តី *ព្រះរាជអាជ្ញា តទល់នឹង Semanza,* អង្គជំនុំជម្រះសាលាដំបូង សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំពន្យាពេលកិច្ចដំណើរការនីតិវិធីសវនាការ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០០ លេខសំណុំរឿង ICTR-97-20-I កថាខណ្ឌ ៤។

[13] រឿងក្តី *ព្រះរាជអាជ្ញា តទល់នឹង Dusko Tadic,* អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកាលើសំណើរបស់មេធាវីការពារក្តីសុំប្តឹងឧទ្ធរណ៍បន្ទាន់បន្ថែមអំពីយុត្តាធិការ ចុះថ្ងៃទី២ ខែតុលា ឆ្នាំ១៩៩៥ លេខសំណុំរឿង IT-94-AR72 កថាខណ្ឌ ៦។

ខ- បញ្ហាណាមួយដែលតម្រូវឲ្យមានការរលត់បណ្តឹងអាជ្ញា

គ- មោឃភាពនីតិវិធីដែលត្រូវបានធ្វើបន្ទាប់ពីមានដីកាដំណោះស្រាយ ត្រូវលើកឡើងយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ បើមិនដូច្នេះទេ អញ្ញត្តកម្មនោះមិនអាចត្រូវបានទទួលយកឡើយ។

២. អង្គជំនុំជម្រះសាលាដំបូង ត្រូវផ្តល់ឲ្យភាគីម្ខាងទៀតនូវឱកាសឆ្លើយតបទៅនឹងអញ្ញត្រកម្ម។

៣. អង្គជំនុំជម្រះសាលាដំបូង នៅពេលសមស្រប ត្រូវសម្រេចជាបន្ទាន់អំពីអញ្ញត្រកម្មតាមសេចក្តីសម្រេចមួយដែល មានសំអាងហេតុ ឬ នៅពេលដំណាលគ្នានឹងសាលក្រមលើអង្គសេចក្តី។ នៅក្នុងករណីដែល អញ្ញត្រកម្មត្រូវបានសម្រេចក្នុងពេលដំណាលគ្នានឹងសាលក្រមលើអង្គសេចក្តី កិច្ចដំណើរការនីតិវិធីត្រូវធ្វើបន្ត។

## III. សេចក្តីសន្និដ្ឋានលើយុត្តាធិការ

### ៣.១ សេចក្តីផ្តើម

៩. មេធាវីការពារក្តីលើកឡើងថា អ.វ.ត.ក គ្មានយុត្តាធិការក្នុងការផ្តន្ទាទោសជនជាប់ចោទចំពោះបទឧក្រិដ្ឋដូចខាងក្រោមនេះទេ៖

- ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (ផ្នែក ៣.៣)
- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ផ្នែក ៣.៤)
- ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ (ផ្នែក ៣.៥)
- ឧក្រិដ្ឋកម្មជាតិ (ផ្នែក ៣.៦)
- ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំដែលមានអំពើអមនុស្សធម៌ផ្សេងទៀតដូចឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ផ្នែក ៣.៧)
- ការរំលោភផ្លូវភេទដែលស្ថិតក្នុងចំណងអាពាហ៍ពិពាហ៍ដោយបង្ខំដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ផ្នែក ៣.៨)
- ការបាត់ខ្លួនដោយបង្ខំដែលជាអំពើអមនុស្សធម៌ផ្សេងទៀតដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ផ្នែក ៣.៩)

១០. លើសពីនេះទៀត មេធាវីការពារក្ដីលើកឡើងថា អ.វ.ត.ក គ្មានយុត្តាធិការក្នុងការផ្ដន្ទាទោសជនជាប់ចោទដោយផ្អែកលើមូលដ្ឋាននៃទម្រង់នៃការទទួលខុសត្រូវដូចខាងក្រោមនេះទេ៖

- សហឧក្រិដ្ឋកម្មរួម (ផ្នែក ៣.១០) និង
- ការទទួលខុសត្រូវរបស់ថ្នាក់លើ (ផ្នែក ៣.១១)។

## ៣.២ គោលការណ៍ច្បាប់ទូទៅ: *គោលការណ៍គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង (Nullum Crimen Sine Lege)*

១១. ជាដំបូង មេធាវីការពារក្ដីលើកឡើងថា *គោលការណ៍គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង (Nullum Crimen Sine Lege)* ហាមឃាត់មិនឲ្យមានការផ្ដន្ទាទោសបទឧក្រិដ្ឋជាច្រើន និងទម្រង់នៃការទទួលខុសត្រូវដូចបានកំណត់នៅក្នុងដីកាដំណោះស្រាយ។ មេធាវីការពារក្ដីលើកឡើងនូវទឡ្ហីករណ៍នេះនៅពេលចាប់ផ្ដើមសេចក្ដីសន្និដ្ឋានរបស់ខ្លួន ពីព្រោះទឡ្ហីករណ៍នេះមានការពាក់ព័ន្ធទៅនឹងអនុផ្នែកនីមួយៗដូចខាងក្រោម។

១២. មាត្រា ៣៣(២) នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក (ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក) ចែងថា គ្មានជនណាម្នាក់ត្រូវបានកំណត់ថាមានពិរុទ្ធអំពីបទល្មើសព្រហ្មទណ្ឌណាមួយដោយសារអំពើណាមួយ ឬអំពើអកម្មណាមួយដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌ ក្រោមច្បាប់ជាតិ ឬច្បាប់អន្តរជាតិ នៅពេលដែលអំពើនោះត្រូវបានប្រព្រឹត្តឡើងនោះទេ។ ចំណុចនេះត្រូវបានបញ្ជាក់ដោយ មាត្រា ៦ នៃក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ និងមាត្រា ១៥(១) នៃ ICCPR។ បន្ថែមពីលើនេះ មាត្រា ១៥(២) នៃ ICCPR ចែងថា "គ្មានបញ្ញត្តិណាមួយនៅក្នុងមាត្រានេះប្រឆាំងនឹងការជំនុំជម្រះក្ដី និងការផ្ដន្ទាទោសដល់ជនណាម្នាក់ចំពោះអំពើណាឬការខកខានណា មួយដែលនៅពេលដែលអំពើនោះត្រូវបានប្រព្រឹត្តឡើង គឺជាបទល្មើសព្រហ្មទណ្ឌយោងតាម គោលការណ៍ច្បាប់ទូទៅដែលត្រូវបានទទួលស្គាល់ដោយសហគមន៍ប្រជាជាតិនោះឡើយ"។

១៣. ដើម្បីអនុវត្តបាននៅចំពោះមុខ អ.វ.ត.ក បទឧក្រិដ្ឋ៖

ក. ត្រូវបានគូសបញ្ជាក់ច្បាស់លាស់នៅក្នុងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក។

ខ. ត្រូវចែងជាបទល្មើសឧក្រិដ្ឋនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។

គ.បង្កើតជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលយុត្តាធិការពេលវេលារបស់តុលាការ។

ឃ. ត្រូវបានចែងជាបទល្មើសនៅក្នុងអនុសញ្ញាអន្តរជាតិដែលអាចអនុវត្តផ្ទាល់ ចំពោះ អ.វ.ត.ក[14]។

១៤. អង្គជំនុំជម្រះសាលាឧទ្ធរណ៍ ICTY បានលើកឡើងថា បទឧក្រិដ្ឋនៃការជម្លៀសមនុស្សដោយបង្ខំ អាចស្ថិតនៅក្រោមប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងទៀត" ពីព្រោះវាត្រូវបានធ្វើឱ្យទៅជាបទល្មើសឧក្រិដ្ឋនៅពេលប្រព្រឹត្តបទល្មើស ហេតុនេះហើយមិនបានរំលោភលើ *គោលការណ៍គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង (Nullum Crimen Sine Lege)* នោះទេ[15]។ ផ្ទុយទៅវិញ គេអាចសន្និដ្ឋានថាប្រសិនបើអំពើជាក់លាក់ណាមួយមិនត្រូវបានចែងជាបទល្មើសនៅពេលពាក់ព័ន្ធទេនោះ វាមិនអាចស្ថិតនៅក្រោមប្រភេទនៃអំពើអមនុស្សធម៌ផ្សេងទៀតបានទេ។

## ៣.៣ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

១៥. មាត្រា ៤ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា "អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដូចមានចែងក្នុងអនុសញ្ញាឆ្នាំ១៩៤៨ ស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ៦ ខែមករា ឆ្នាំ១៩៧៩"។ ច្បាប់ស្តីពីបង្កើត អ.វ.ត.ក បានអនុម័តនិយមន័យនៃពាក្យ "ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍" ដូចគ្នានឹង

[14] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ២។

[15] សូមមើលរឿងក្តី *ព្រះរាជអាជ្ញា តទល់នឹង Stakic*, សាលក្រម លេខសំណុំរឿង IT-97-24-A ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ៣១៧ ត្រង់ចំណុចដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍លើកឡើងថា: "អង្គជំនុំជម្រះសាលាឧទ្ធរណ៍កត់សម្គាល់ឃើញថា មាត្រា ២(ឆ) នៃច្បាប់លក្ខន្តិកៈ មាត្រា ៤៩ និង ១៤៧ នៃអនុសញ្ញាទីក្រុងហ្សឺណែវ IV មាត្រា ៨៥(៤)(ក) នៃពិធីសារបន្ថែម I និងមាត្រា ១៨ នៃសេចក្តីព្រាងក្រម ILC ឆ្នាំ១៩៩៦ ទាំងអស់ផ្តន្ទាទោសដល់ការជម្លៀសមនុស្សដោយបង្ខំ។ ហេតុដូច្នេះ សញ្ញាណនៃការជម្លៀសមនុស្សដោយបង្ខំត្រូវបានយល់ព្រមយ៉ាងច្បាស់លាស់ថាជាការប្រព្រឹត្តដែលត្រូវបានធ្វើឱ្យទៅជាបទល្មើសឧក្រិដ្ឋនៅពេលពាក់ព័ន្ធទៅនឹងករណីនេះ ដូចនេះ វាមិនរំលោភលើ *គោលការណ៍គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង (Nullum Crimen Sine Lege)* នោះទេ"។

អនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[16]។

១៦. មេធាវីការពារក្តីលើកឡើងថា អ.វ.ត.ក ខ្វះយុត្តាធិការក្នុងការកាត់សេចក្តីជនជាប់ចោទចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍។ ការកាត់សេចក្តីនេះនឹងរំលោភលើ *គោលការណ៍គ្រឹះ គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង (Nullum Crimen Sine Lege)* ។ ដោយសារចំនួនទំព័រនៃអញ្ញត្រកម្មនេះមានកំណត់ មេធាវីការពារក្តីសូមបញ្ចូលនូវទឡ្ហីករណ៍នានាដោយសេចក្តីយោងដែលត្រូវបានថ្លែងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនពាក់ព័ន្ធនឹងបញ្ហានេះជាសំអាង [17] និងសន្និដ្ឋានថា អ.វ.ត.ក គ្មានយុត្តាធិការក្នុងការកាត់សេចក្តីជនជាប់ចោទចំពោះបទឧក្រិដ្ឋនេះទេ។

## ៣.៤ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

១៧. មេធាវីការពារក្តីលើកឡើងថា អ.វ.ត.ក គ្មានយុត្តាធិការក្នុងការកាត់សេចក្តីជនជាប់ចោទចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះទេ។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិមិនត្រូវបានច្បាប់ចែងជាបទល្មើសឧក្រិដ្ឋនៅក្នុងប្រទេសកម្ពុជានៅពេលពាក់ព័ន្ធនោះទេ ហេតុនេះហើយ គ្មានយុត្តាធិការក្នុងការកាត់សេចក្តីជនជាប់ចោទចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិនោះទេ ហើយការធ្វើដូច្នេះ នឹងរំលោភលើ *គោលការណ៍គ្រឹះ គ្មានបទល្មើសប្រសិនបើគ្មានច្បាប់ចែង (Nullum Crimen Sine Lege)* ។ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនមានបទបញ្ញត្តិដែលចែងអំពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិក្នុងប្រទេសកម្ពុជានោះទេ។

១៨. ដោយសារតែចំនួនអញ្ញត្រកម្មទាំងអស់នេះមានកំណត់ មេធាវីការពារក្តីសូមបញ្ចូលនូវសេចក្តីយោងនៃទឡ្ហីករណ៍នានាដែលត្រូវបានថ្លែងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួនពាក់ព័ន្ធនឹងបញ្ហានេះជាសំអាង[18]។

---

[16] អនុសញ្ញាស្តីពីការការពារ និងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ត្រូវបានអនុម័តដោយសេចក្តីសម្រេច ២៦០ (III) ក នៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨ ចូលជាធរមាន: ថ្ងៃទី១០ ខែមករា ឆ្នាំ១៩៥១ មាត្រា ២ និង ៣។ បណ្តឹងឧទ្ធរណ៍ ផ្នែក ៣.៣ - ឧក្រិដ្ឋកម្មសង្គ្រាម។

[17] បណ្តឹងឧទ្ធរណ៍ ផ្នែក ៣.៣ - ឧក្រិដ្ឋកម្មសង្គ្រាម។

[18] បណ្តឹងឧទ្ធរណ៍ ផ្នែក ៣.៤ - ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។

## ៣.៥ ការរំលោភបំពានធ្ងន់ធ្ងរ

១៩. ការអនុវត្តការរំលោភបំពានធ្ងន់ធ្ងរត្រូវបានកំណត់ដោយដីកាដំណោះស្រាយចំពោះ "មន្ទីរសន្តិសុខ ស២១ នៅមន្ទីរសន្តិសុខអូរកន្សែង និងនៅក្នុងការលុកលុយចូលទៅប្រទេសវៀតណាមដោយកងទ័ពបដិវត្តកម្ពុជា" (RAK)[19]។ ដូចគ្នាដែរ ពាក់ព័ន្ធនឹងការពិភាក្សាផ្លូវច្បាប់អំពីយុត្តាធិការចំពោះការរំលោភបំពានធ្ងន់ធ្ងរ មេធាវីការពារក្តីសូមបញ្ចូលដោយសេចក្តីយោងនូវទឡ្ហីករណ៍នានាដែលត្រូវបានថ្លែងនៅក្នុង បណ្តឹងឧទ្ធរណ៍របស់ខ្លួនជាសំអាង[20]។

## ៣.៦ បទឧក្រិដ្ឋថ្នាក់ជាតិ

២០. មេធាវីការពារក្តីសន្និដ្ឋានថា អ.វ.ត.ក មិនមានយុត្តាធិការក្នុងការជំនុំជម្រះក្តីជនជាប់ចោទចំពោះបទឧក្រិដ្ឋថ្នាក់ជាតិទេ។ ដើម្បីជាការគាំទ្រដល់ទឡ្ហីករណ៍របស់ខ្លួន មេធាវីការពារក្តីសូមយោងទៅដល់ផ្នែក៣.៦ នៃបណ្តឹងឧទ្ធរណ៍នេះ និងផ្នែក IV នៃសារណាតប[21]។

២១. នៅក្នុងសំណុំរឿង *ឌុច* អង្គជំនុំជម្រះសាលាដំបូងខកខានមិនអាចចេញសេចក្តីសម្រេចដោយសំឡេងភាគច្រើន ហេតុនេះអង្គជំនុំជម្រះនេះមិនអាចជំនុំជម្រះ ឌុច ចំពោះបទឧក្រិដ្ឋថ្នាក់ជាតិបានទេ[22]។ សហព្រះរាជអាជ្ញា មិនបានប្តឹងសាទុក្ខចំពោះការសម្រេចនេះទេ ហេតុនេះចាត់ទុកថាស្របទៅនឹងអង្គច្បាប់នេះ។

២២. មេធាវីការពារក្តីសន្និដ្ឋានថា ការជំនុំជម្រះលើបទឧក្រិដ្ឋថ្នាក់ជាតិត្រូវបានរារាំងដោយអាជ្ញាយុកាលនៃបទល្មើស។ ការពន្លាតរយៈពេលដើម្បីអនុញ្ញាតឱ្យធ្វើការជំនុំជម្រះនោះ គឺជាការរំលោភបំពានដល់គោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌ ពោលគឺគោលការណ៍ *គ្មានបទល្មើសបើគ្មានច្បាប់ចែង*។

---

[19] ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៧៩។

[20] បណ្តឹងឧទ្ធរណ៍ ផ្នែក ៣.៥ - ការរំលោភបំពានធ្ងន់ធ្ងរ។

[21] សារណាតបរបស់មេធាវីការពារក្តី ទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១០ ឯកសារលេខ D427/2/11។

[22] អង្គជំនុំជម្រះសាលាដំបូង សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងថិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិ ដែលលើកឡើងដោយមេធាវីការពារក្តី សំណុំរឿងលេខ០០១ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារលេខ E187។

ជាការគួរឲ្យចាប់អារម្មណ៍នោះគឺថា មាត្រា៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បានហាមឃាត់មិនឲ្យមានការអនុវត្តច្បាប់បែបប្រតិសកម្មឡើយ។

២៣. មេធាវីការពារក្តីសន្និដ្ឋានបន្ថែមទៀតថា គោលការណ៍ទូទៅមួយទៀតរបស់ច្បាប់ព្រហ្មទណ្ឌចែងថា ច្បាប់ព្រហ្មទណ្ឌត្រូវតែចែងសម្រាប់សាធារណជនទូទៅ មិនមែនសំដៅតែទៅលើក្រុមបុគ្គលណាមួយជាក់លាក់ទេ។ មាត្រា៣(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានរំលោភទៅដល់គោលការណ៍នេះ ហេតុនេះវាក៏រំលោភដល់សិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានសមភាព ដែលការពន្យាររយៈពេលអាជ្ញាយុកាលគឺ ត្រឹមតែយកទៅអនុវត្ត ដើម្បីជំនុំជម្រះបុគ្គលដែលត្រូវបាននាំខ្លួនមក អ.វ.ត.ក ប៉ុណ្ណោះ ដោយសារពួកគេត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តក្នុងអំឡុងពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ និងខកខានមិនបានពន្យាររយៈពេលអាជ្ញាយុកាលដូចគ្នានេះ ចំពោះបទឧក្រិដ្ឋកម្មដទៃទៀតដែលស្រដៀងគ្នា ដែលបានប្រព្រឹត្តក្នុងអំឡុងពីឆ្នាំ១៩៧៩ ដល់ឆ្នាំ២០០៣។ ហេតុនេះច្បាប់នេះចែងឡើង ដើម្បីសំដៅដល់ក្រុមបុគ្គលជាក់លាក់ និងមិនមែនសម្រាប់សាធារណជនទូទៅទេ ដែលនេះជាការរំលោភបំពានដល់គោលការណ៍ទូទៅ នៃសិទ្ធិទទួលបានការប្រព្រឹត្តស្មើគ្នា សម្រាប់រឿងក្តីដូចគ្នា។ នេះជាការរើសអើងចំពោះជនជាប់ចោទ។

២៤. ផ្អែកលើមូលដ្ឋាននេះ ការអនុវត្តមាត្រា៣(ថ្មី) នៃច្បាប់ស្តីពីការបង្កើត គួរត្រូវបានច្រានចោល។

## ៣.៨ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និង ការរំលោភផ្លូវភេទក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

២៥. ដូចដែល ក.ស.ច.ស បានទទួលស្គាល់រួចមកហើយនៅក្នុងដីកាដំណោះស្រាយគឺថា ការអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អ.វ.ត.ក តម្រូវថា ការវាយប្រហារត្រូវតែបានប្រព្រឹត្តឡើងដោយផ្អែកទៅលើ "មូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា"[23]។ ចំណុចនេះជាការបន្ថែមទៅលើនិយមន័យនៃពាក្យថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងទំនៀមទម្លាប់អន្តរជាតិ និង "ជាកំហិតមួយដែលបានបង្កើតឡើងដោយច្បាប់ចំពោះយុត្តាធិការរបស់ អ.វ.ត.ក"[24]។ ក.ស.ច.ស អះអាងថា ពួកគេពិតជានឹងអនុវត្តតាមន័យចង្អៀត ក្នុងការបកស្រាយមាត្រា៥ នៃ

---

[23] ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៥។

[24] *ដូចជើងទំព័រខាងលើ។*

ច្បាប់ អ.វ.ត.ក[25]។ ទោះបីជាយ៉ាងនេះក្តី ពួកគេខកខានមិនបានធ្វើបែបនេះទេ នៅក្នុងការវិភាគអំពីឧក្រិដ្ឋកម្មពីរដែលត្រូវបានចោទប្រកាន់គឺ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

២៦. ចាប់ពីកថាខណ្ឌ១៣១៣ ដល់កថាខណ្ឌ១៣១៥ នៃដីកាដំណោះស្រាយ បានរៀបរាប់ពីនិយមន័យមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវអនុវត្តនៅ អ.វ.ត.ក។ មេធាវីការពារក្តីលើកឡើងថានិយមន័យនេះបានបដិសេធចោលនូវយុត្តាធិការបច្ចុប្បន្នរបស់ អ.វ.ត.ក ទៅលើឧក្រិដ្ឋកម្មនេះជាទូទៅ (ផ្នែក៣.៤)។ ប៉ុន្តែ មេធាវីការពារក្តីក៏បានលើកបញ្ហានេះដោយមានការអនុវត្តជាក់លាក់ផងមកពិភាក្សាទាក់ទិននឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលឧក្រិដ្ឋកម្មទាំងពីរត្រូវបានចោទប្រកាន់ថាជាអំពើអមនុស្សធម៌ផ្សេងៗទៀត។

### ៣.៨.១ *ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ/ការដាក់កំហិតលើការរៀបអាពាហ៍ពិពាហ៍ជា "អំពើអមនុស្សធម៌ផ្សេងៗទៀត"* [26]

២៧. ដីកាដំណោះស្រាយបានកំណត់និយមន័យនៃពាក្យ "គោលនយោបាយ" ឧក្រិដ្ឋមួយក្នុងចំណោមគោលនយោបាយឧក្រិដ្ឋចំនួន៥របស់ពួកខ្មែរក្រហមថាជា "ការដាក់កំហិតលើការរៀបអាពាហ៍ពិពាហ៍ តាមរយៈមធ្យោបាយណាក៏ដោយឱ្យតែចាំបាច់"[27]។ មេធាវីការពារក្តីសន្និដ្ឋានថា "ការដាក់កំហិតលើការរៀបអាពាហ៍ពិពាហ៍" មិនគួរចាត់ទុកថាជាឧក្រិដ្ឋកម្មអន្តរជាតិនៅក្នុងចង្កោមឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទេ។ "ឧក្រិដ្ឋកម្ម" ដែលត្រូវបានចោទប្រកាន់នេះ មិនត្រូវបានកំណត់និយមន័យនៅក្នុងដីកាដំណោះស្រាយទេ ដែលជួនកាលត្រូវបានគេហៅថា "ការដាក់កំហិត"[28] និង

---

[25] *ដូចដើងទំព័រខាងលើ។*

[26] សូមមើលផងដែរ សេចក្តីឆ្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី សុំឱ្យមានកិច្ចស៊ើបសួរ ស្តីអំពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងផ្លូវភេទដោយបង្ខំ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៩ ឯកសារលេខ D188/3។

[27] ដីកាដំណោះស្រាយ កថាខណ្ឌ ២១៦។

[28] សូមមើលជាឧទាហរណ៍ ដីកាដំណោះស្រាយ នៅទំព័រ២០៩។

នៅពេលខ្លះទៀតជា "ឧក្រិដ្ឋកម្មនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ"[29] ដែលមានការបង្កប់ន័យខុសគ្នាទាំងស្រុង។ ខ្លឹមសារនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ទាំងនេះមិនត្រូវបានកំណត់និយមន័យឱ្យបានពេញលេញទេ ឧទាហរណ៍ មានការសន្និដ្ឋានថា៖ "សាក្សីមួយចំនួនអះអាងថាពួកគេត្រូវបានបង្ខំឱ្យរួមដំណេក ដែលចំណុចនេះស៊ីសង្វាក់ទៅនឹងអត្ថិភាពនៃផែនការរួម ដែលបង្កើតឡើងដោយមេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា ហើយតាមរយៈនេះ ការរៀបអាពាហ៍ពិពាហ៍ជាការចាំបាច់ដើម្បីបង្កើនចំនួនប្រជាជន"[30]។ មេធាវីការពារក្តីមិនបានឆ្លើយតបទៅនឹងបញ្ហានានានៃភ័ស្តុតាងដែលនៅក្នុងចំណុចនេះទេ។

២៨. ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នេះមិនស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ទេ ដោយសារវាមិនត្រូវបានកំណត់និយមន័យនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ ឧក្រិដ្ឋកម្មនេះមិនត្រូវបានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ហើយក៏មិនមែនជាផ្នែកមួយនៃច្បាប់ទម្លាប់អន្តរជាតិនៅក្នុងអំឡុងពេលដែលពាក់ព័ន្ធដែរ។ កម្ពុជាមិនមែនជាភាគីនៃអនុសញ្ញាអន្តរជាតិណាមួយដែលពាក់ព័ន្ធដល់ឧក្រិដ្ឋកម្មនេះនៅពេលនោះទេ ហើយក៏មិនស្ថិតក្នុងអំឡុងពេលដែលពាក់ព័ន្ធដែរ។

### ៣.៨.២ *ការរំលោភផ្លូវភេទនៅក្នុងការរៀបអាពាហ៍ពិពាហ៍ជាអំពើអមនុស្សធម៌ផ្សេងៗទៀត*

២៩. ជនជាប់ចោទត្រូវបានចោទប្រកាន់ដាច់ដោយឡែកពីគ្នានូវការរំលោភផ្លូវភេទ និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ជាអំពើអមនុស្សធម៌ផ្សេងៗទៀត[31]។ មេធាវីការពារក្តីសន្និដ្ឋានថា ក្រៅពីអង្គហេតុដែលថា អ.វ.ត.ក មិនមានយុត្តាធិការជំនុំជម្រះក្តីលើឧក្រិដ្ឋកម្មនេះ ធាតុផ្សំនៃអង្គច្បាប់ដើម្បីចាត់ទុកជាការរំលោភផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងប្រភេទនៃអំពើអមនុស្សធម៌ផ្សេងៗទៀតមិនត្រូវបានបំពេញឡើយ។

៣០. មេធាវីការពារក្តីសន្និដ្ឋានថា ឧក្រិដ្ឋកម្មនេះមិនត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ពេញលេញនៅក្នុងដីកាដំណោះស្រាយទេ ហើយសាលដីការបស់ អ.ប.ជ ក៏មិនទាន់បានផ្តល់ព័ត៌មានពិស្តារនៅឡើយ

---

[29] សូមមើលជាឧទាហរណ៍ ដីកាដំណោះស្រាយ កថាខណ្ឌ៨៦១។

[30] ដីកាដំណោះស្រាយ កថាខណ្ឌ១៤៤៧។

[31] បណ្តឹងឧទ្ធរណ៍ អ.ប.ជ ទំព័រ៤ ក្រោមចំណុច២។

ដែរ។ នៅមានបញ្ហាដែលជាប់មកជាមួយនឹងឧក្រិដ្ឋកម្មនេះ ដែលត្រូវបានបង្កើតឡើងនៅក្នុងដីកាដំណោះស្រាយ។ ឧក្រិដ្ឋកម្មនៃការរំលោភផ្លូវភេទនៅក្នុងការរៀបអាពាហ៍ពិពាហ៍ដែលត្រូវបានចោទប្រកាន់ មិនបានឆ្លើយដាក់ជនជាប់ចោទ និង/ឬ សហជនជាប់ចោទរបស់គាត់ ថាជាភាគីនៃអំពើរំលោភផ្លូវភេទនោះទេ។ ទោះបី ចុងចោទអាចនឹងមិនត្រូវបានទទួលការជំនុំជម្រះទោសពីបទរំលោភផ្លូវភេទ ដោយសារគាត់មិនមែនជាអាទិចារីក៏ដោយ តែគាត់ក៏អាចនឹងត្រូវទទួលការជំនុំជម្រះទោសផងដែរ ដោយសារការទទួលខុសត្រូវដោយប្រយោលរបស់ខ្លួន។ ការលំបាកចំពោះឧក្រិដ្ឋកម្មជាក់លាក់នេះគឺថា គេមិនអាចកំណត់អត្តសញ្ញាណចារីបាន ក្រៅពីពិរុទ្ធភាពរបស់ថ្នាក់លើ តែថ្នាក់លើមិនអាចចាត់ទុកថាមានពិរុទ្ធភាពបានទេ ប្រសិនបើមិនមានឧក្រិដ្ឋកម្មដែលបានលើកឡើងនោះ។ កត្តាអត្តនោម័ត និងកត្តាសត្យានុម័តពុំត្រូវបានកំណត់ថាមាននៅក្នុងបុគ្គលណាម្នាក់ទេ តែប្រសិនបើមានក៏មាននៅក្នុងមនុស្សជាច្រើននាក់ដែរ។ ជាក់ស្តែង ក្នុងករណីដែលប្តីប្រពន្ធរំលោភគ្នាទៅវិញទៅមក មានន័យថាតើនេះជាទម្រង់នៃការរំលោភផ្លូវភេទទៅវិញទៅមកឬ? ការចាត់ទុកថាជាពិរុទ្ធភាពរបស់ថ្នាក់លើ ពីអំពើរំលោភផ្លូវភេទនៅក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ គេក៏ត្រូវចាត់ទុកជាឧក្រិដ្ឋកម្មផងដែរនូវសកម្មភាពរបស់ភាគីដែលបានប្រព្រឹត្តអំពើរួមសេពសន្ថវៈ។ ការរួមដំណេកអាចក្លាយជាឧក្រិដ្ឋកម្ម ថ្វីត្បិតតែប្តីប្រពន្ធមិនបានទទួលខុសត្រូវដោយផ្ទាល់ចំពោះឧក្រិដ្ឋកម្មប្រភេទនេះក៏ដោយ។ ហេតុនេះការកំណត់ជាឧក្រិដ្ឋកម្មបែបនេះនឹងលេចចេញជាបញ្ហា ហើយការជំនុំជម្រះទោសមិនអាចធ្វើទៅបានទេ។ អាស្រ័យហេតុនេះ មេធាវីការពារក្តីស្នើសុំ អង្គជំនុំជម្រះសាលាដំបូងមិនត្រូវឲ្យមានការជំនុំជម្រះទៅលើឧក្រិដ្ឋកម្មនេះទេ។

## ៣.៩ ការបាត់ខ្លួនដោយបង្ខំ

៣១. នៅក្នុង “ចម្លើយតបរួមរបស់មេធាវីការពារក្តីទៅនឹងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំ” មេធាវីការពារក្តីកសន្និដ្ឋានថា អ.វ.ត.ក មិនមានយុត្តាធិការជំនុំជម្រះក្តីជនជាប់ចោទ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការបាត់ខ្លួនដោយបង្ខំទេ[32]។ មេធាវីការពារក្តីសូមលើកយកទឡ្ហីករណ៍មកសំអាងជាលក្ខណៈយោងដូចខាងក្រោម។

---

[32] ចម្លើយតបរួមរបស់មេធាវីការពារក្តីទៅនឹងសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៩ ឯកសារលេខ D180/2។

៣២. ឧក្រិដ្ឋកម្មនៃការបាត់ខ្លួនដោយបង្ខំជាអំពើអមនុស្សធម៌ផ្សេងៗទៀត មិនមែនជាសមត្ថកិច្ចយុត្តាធិការរបស់ អ.វ.ត.ក ទេ ដោយសារវាមិនមែនជាឧក្រិដ្ឋកម្មនៅពេលវេលាដែលពាក់ព័ន្ធឡើយ។ អាស្រ័យហេតុនេះ ការជំនុំជម្រះទោសដោយផ្អែកលើមូលដ្ឋាននេះនឹងរំលោភដល់គោលការណ៍ *គ្មានបទល្មើសបើគ្មានច្បាប់ចែង* (*nullum crimen sine lege*)។ ឧក្រិដ្ឋកម្មនេះមិនមានចែងក្នុងច្បាប់ស្តីពីការបង្កើតទេ អ.វ.ត.ក វាក៏មិនមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ហើយក៏មិនមែនជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលវេលាដែលពាក់ព័ន្ធដែរ[33]។ ម្យ៉ាងវិញទៀត ប្រទេសកម្ពុជាមិនមែន ជាភាគីនៃអនុសញ្ញាអន្តរជាតិណាមួយដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនេះ នៅសម័យនោះទេ។ មានអនុសញ្ញាមួយដែលទាក់ទិននឹងឧក្រិដ្ឋកម្មស្រដៀងគ្នានេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៦ តែប្រទេសកម្ពុជាមិនមែនជាភាគីនៃអនុសញ្ញានេះទេ ហើយអនុសញ្ញានេះក៏ទើបតែបានចូលជាធរមានកាលពីពីរខែមុនប៉ុណ្ណោះ[34]។ ជាងនេះទៀត និយមន័យដែលមានកំណត់នៅក្នុងអនុសញ្ញានេះបង្ហាញពីលក្ខខណ្ឌតឹងរ៉ឹងដែលកំណត់ពីឧក្រិដ្ឋកម្មនាពេលបច្ចុប្បន្ននេះ[35]។

## ៣.១០ សហឧក្រិដ្ឋកម្មរួម

៣៣. ជាច្រើនលើកច្រើនសារមកហើយ មេធាវីការពារក្តីជនជាប់ចោទបានបង្ហាញពីការជំទាស់ទៅលើយុត្តាធិការក្នុងការជំនុំជម្រះទោស ដោយផ្អែកលើមូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួម (JCE)[36]។ នៅក្នុង

---

[33] សារណារបស់ Antonio Cassese, *International Criminal Law* (2003), ទំព័រ 80 និង 94។

[34] សូមមើល "អនុសញ្ញាអន្តរជាតិស្តីពីការការពារជនគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ" ចូលមើលថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០០៩ នៅគេហទំព័រ http://treaties.un.org/Pages/ViewDetails.aspx?src=TREATY&mtdsg_no=IV-16&chapter=4&lang=en

[35] មាត្រា២ នៃអនុសញ្ញានេះកំណត់និយមន័យនៃពាក្យ "បាត់ខ្លួនដោយបង្ខំ" ថាជា "ការចាប់ខ្លួន ការឃុំខ្លួន ការចាប់ពង្រត់ ឬទម្រង់ដទៃទៀតនៃការដកហូតសេរីភាព ដោយភ្នាក់ងាររដ្ឋ ឬដោយបុគ្គល ឬដោយក្រុមមនុស្សដែលធ្វើសកម្មភាពដោយមានអំណាច ការគាំទ្រ ឬការទទួលស្គាល់ពីរដ្ឋ ដោយមានការបដិសេធមិនទទួលស្គាល់ការដកហូតសេរីភាព ឬដោយការបិទបាំងពីជោគវាសនា ឬពីដំណឹងនៃជនដែលបានបាត់ខ្លួន ដែលដាក់ជនណាម្នាក់ឲ្យនៅក្រៅពីការការពារដោយច្បាប់"។

[36] បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីរបស់អ្នកស្រី អៀង ធីរិទ្ធ ចំពោះ "ដីកាសម្រេចអំពីការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលត្រូវបានទទួលស្គាល់ថាជាសហឧក្រិដ្ឋកម្មរួម" ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៩ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០១០ ឯកសារលេខ D97/15/1។

ឯកសារនោះ មេធាវីការពារក្តីបានលើកឡើងយ៉ាងពេញលេញថា ទម្រង់ទីបីដែលជាទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួម (JCE III) មិនគួរយកមកអនុវត្តនៅ អ.វ.ត.ក ទេ ជាអនុសាសន៍មួយដែលពិតជាឆ្លុះបញ្ចាំងនៅក្នុងសាលដីការបស់ អ.ប.ជ ស្តីពីការអនុវត្តនៃសហឧក្រិដ្ឋកម្មរួម ដែលនៅក្នុងសាលដីកានោះ អ.ប.ជ បានសម្រេចថា៖

> ដោយបានពិនិត្យមើលទៅលើអាជ្ញាធរដែល *រឿងក្តី Tadic* បានផ្អែកទៅលើនោះ ទាក់ទិនទៅនឹងទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួម អង្គបុរេជំនុំជម្រះបានទស្សនៈថា ពួកគាត់មិនបានផ្តល់នូវភ័ស្តុតាងគ្រប់គ្រាន់អំពីទស្សនៈច្បាប់ និងការអនុវត្តរបស់រដ្ឋ ដែលមានលក្ខណៈទូលំទូលាយ និងស៊ីគ្នាឡើយ នៅពេលវេលាដែលពាក់ព័ន្ធសម្រាប់សំណុំរឿង ០០២។ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា JCE III មិនត្រូវបានទទួលស្គាល់ជាទម្រង់នៃការទទួលខុសត្រូវ ដែលអាចអនុវត្តចំពោះការរំលោភបំពានលើច្បាប់មនុស្សធម៌អន្តរជាតិឡើយ [...][37]។

៣៤. ដោយសារ JCE III មិនត្រូវបានដាក់បញ្ចូលនៅក្នុងសេចក្តីសម្រេចរបស់ អ.ប.ជ នោះ មេធាវីការពារក្តីនឹងផ្តោតតែទៅលើទម្រង់ពីរផ្សេងទៀតនៃសហឧក្រិដ្ឋកម្មរួមគឺ៖ JCE I និង JCE II។ នៅក្នុងសារណារបស់ខ្លួនស្តីពីសហឧក្រិដ្ឋកម្មរួម ដាក់ជូនសហចៅក្រមស៊ើបអង្កេត[38] មេធាវីការពារក្តីបានរៀបរាប់ពីលក្ខខណ្ឌចាំបាច់នានាដើម្បីឱ្យ បញ្ញត្តិស្តីពីសហឧក្រិដ្ឋកម្មរួមអាចយកទៅអនុវត្ត

---

[37] អ.ប.ជ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារលេខ D97/15/9 កថាខណ្ឌ៧៧។

[38] សារណារបស់អ្នកស្រី អៀង ធីរិទ្ធ ស្តីពីការអនុវត្ត នៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវដែលគេស្គាល់ថាសហឧក្រិដ្ឋកម្មរួមអនុលោមតាមដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៨, ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៨ ឯកសារលេខ D97/3/2។

បាន។ មេធាវីការពារក្តីក៏បានឯកភាពទៅលើទឡ្ហីករណ៍ដែលបានរៀបរាប់នៅក្នុងពាក្យស្នើសុំ[39] និងសេចក្តីសង្កេតបន្ថែម[40] របស់លោក អៀង សារី។

៣៥. នៅក្នុងសារណារបស់ខ្លួនដែលមិនមែនជាភាគីនៃរឿងក្តីដែលបានដាក់ជូនអង្គបុរេជំនុំជម្រះក្នុងសំណុំរឿង០០១ លោក Kai Ambos បានលើកឡើងថា តម្រូវឲ្យបំពេញតាមលក្ខខណ្ឌបួនគឺ[41]៖

(i) សហឧក្រិដ្ឋកម្មរួមត្រូវមាននៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅពេលវេលាសមស្រប។
(ii) សហឧក្រិដ្ឋកម្មរួមត្រូវតែជាផ្នែកមួយនៃច្បាប់កម្ពុជានៅពេលវេលាដែលពាក់ព័ន្ធនោះ។
(iii) សហឧក្រិដ្ឋកម្មរួមត្រូវតែមានការទទួលដឹងគ្រប់គ្រាន់ និងអាចប្រមើលមើលដឹងជាមុនចំពោះចុងចោទនៅក្នុងពេលវេលាដែលពាក់ព័ន្ធនោះ។
(iv) បន្ថែមពីលើនេះទៀត ច្បាប់ដែលអនុវត្តនៅ អ.វ.ត.ក ត្រូវតែមានចែងអំពីទម្រង់នៃការទទួលខុសត្រូវនេះ។

៣៦. មេធាវីការពារក្តីឯកភាពតាមការវិភាគរបស់ Kai Ambos និងសេចក្តីសន្និដ្ឋានរបស់គាត់ដែលថា មានតែសហឧក្រិដ្ឋកម្មរួមទម្រង់ទីមួយទេ ដែលមានចែងយ៉ាងច្បាស់នៅក្នុងច្បាប់កម្ពុជានៅពេលវេលាដែលពាក់ព័ន្ធនោះ។ ការយកសហឧក្រិដ្ឋកម្មរួមទម្រង់ទីពីរមកអនុវត្តគឺមិនមានភាពច្បាស់លាស់ និងមិនប្រាកដប្រជាឡើយ ហេតុនេះគេមិនគួរផ្អែកលើទម្រង់នេះទេ ព្រោះវាអាចធ្វើឲ្យខូចប្រយោជន៍ដល់ជនត្រូវចោទ[42]។

---

[39] ពាក្យស្នើសុំរបស់លោក អៀង សារី ប្រឆាំងនឹងការអនុវត្តនៅ អ.វ.ត.ក នូវទម្រង់នៃការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ដែលគេហៅថា *សហឧក្រិដ្ឋកម្មរួម* (JCE) ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៨ ឯកសារលេខ D97។

[40] សេចក្តីសង្កេតបន្ថែមរបស់លោក អៀង សារី ស្តីពីការអនុវត្តទ្រឹស្តី សហឧក្រិដ្ឋកម្មរួម នៅ អ.វ.ត.ក ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារលេខ D97/7។

[41] សារណារបស់អ្នកដែលមិនមែនភាគីនៃរឿងក្តី ពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌលេខ ០០១/១៨-០៧-២០០៧-អវតក/កសចស (អបជ០២) ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៨ ឯកសារលេខ D99/3/27 (សំណុំរឿងលេខ ០០១) ទំព័រ២១។

[42] អត្ថបទរបស់ Kai Ambos មានចំណងជើងថា *សារណារបស់អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ទំព័រ30។

00643979



៣៧. ជាងនេះទៅទៀត មេធាវីការពារក្តីសន្និដ្ឋានថា ការអនុវត្ត និងការបកស្រាយសហឧក្រិដ្ឋកម្មរួមគឺមានការខ្វែងគំនិតគ្នាយ៉ាងទូលំទូលាយ ហើយប្រសិនបើយកមកអនុវត្តវិញ នឹងមានការបកស្រាយផ្សេងៗ ផ្ទុយគ្នាជាច្រើនទៅលើខ្លឹមសារជាក់លាក់របស់វា ដូចដែលធ្លាប់បានបង្ហាញទស្សនៈផ្សេងៗគ្នាជាច្រើនរួចមកហើយក្នុងការពិភាក្សាពីការអនុវត្តទម្រង់នេះនៅក្នុងសំណុំរឿង០០១។ ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ បានចែងពីទម្រង់ពីរនៃការទទួលខុសត្រូវ គឺការចូលរួមប្រព្រឹត្ត និងការសមគំនិត ដែលស្រដៀងគ្នាជាខ្លាំងទៅនឹងទម្រង់ជាមូលដ្ឋាន និងទម្រង់ទីពីរនៃសហឧក្រិដ្ឋកម្មរួម។ ជាបឋម អ.វ.ត.ក គួរអនុវត្តច្បាប់កម្ពុជាជាមុនសិន ហើយគួរត្រូវផ្អែកលើក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ជាជាងយកទម្រង់នៃការទទួលខុសត្រូវតាមច្បាប់អន្តរជាតិដែលមានភាពចម្រូងចម្រាសមកអនុវត្ត។

៣៨. អាស្រ័យហេតុនេះ មេធាវីការពារក្តីសន្និដ្ឋានថា អ.វ.ត.ក មិនមានយុត្តាធិការចាំបាច់ក្នុងការជំនុំជម្រះសេចក្តីទៅលើទម្រង់នៃការទទួលខុសត្រូវនេះទេ។

## ៣.១១ ការទទួលខុសត្រូវរបស់ថ្នាក់លើ

៣៩. ដីកាដំណោះស្រាយបានចោទប្រកាន់ជនជាប់ចោទពីការទទួលខុសត្រូវរបស់ថ្នាក់លើ ជាទម្រង់នៃការទទួលខុសត្រូវមួយទាក់ទិននឹងឧក្រិដ្ឋកម្មចំនួនបី ដែលស្ថិតនៅក្នុងចង្កោមឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[43]៖

(ក). អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់នៃ "ការប៉ះពាល់ដល់ភាពថ្លៃថ្នូរជាមនុស្ស" និងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

(ខ). ការរំលោភផ្លូវភេទក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។

(គ). ការធ្វើទុក្ខបុកម្នេញលើជនជាតិវៀតណាមដោយសារមូលហេតុពូជសាសន៍ ។

៤០. ជនជាប់ចោទត្រូវបានចោទប្រកាន់ថាបាន "ខកខានមិនបានចាត់វិធានការចាំបាច់នានា ដើម្បីបង្ការកុំឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ" ហើយ "អៀង ធីរិទ្ធ បានដឹង ឬមានហេតុផលក្នុងការដឹងថា ឧក្រិដ្ឋកម្មទាំងនេះត្រូវបានប្រព្រឹត្តយ៉ាងជាក់ស្តែង ដោយអ្នកក្រោមបង្គាប់របស់ខ្លួន ហើយខ្លួន

[43] ដីកាដំណោះស្រាយ កថាខណ្ឌ ១៥៦១។

បានខកខានមិនបានដាក់ទោសចារីទាំងនោះ" [44] ។ មេធាវីការពារក្តីសូមយោងទៅលើទឡ្ហីករណ៍ដែលមានរៀបរាប់នៅក្នុងផ្នែក ៣.៨ នៃបណ្តឹងឧទ្ធរណ៍ និងផ្នែក VIII នៃសារណាតបរបស់ខ្លួន[45] និងសូមសន្និដ្ឋានថា អ.វ.ត.ក មិនមានយុត្តាធិការជំនុំជម្រះក្តីអ្នកជាប់ចោទ ចំពោះទម្រង់នៃការទទួលខុសត្រូវនេះទេ។

## IV. សន្និដ្ឋាន

៤១. មេធាវីការពារក្តីសូមស្នើអង្គជំនុំជម្រះសាលាដំបូងមេត្តាសម្រេចទៅលើអញ្ញត្តកម្មទាំងនេះបន្ទាប់ពីបានបើកសវនាការបឋម មុនពេលចាប់ផ្តើមសវនាការជំនុំជម្រះ។

៤២. មេធាវីការពារក្តីសូមស្នើបន្ថែមដល់អង្គជំនុំជម្រះសាលាដំបូងមេត្តាសម្រេចថា អ.វ.ត.ក មិនមានយុត្តាធិការក្នុងការជំនុំជម្រះជនជាប់ចោទពីឧក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវនានាដែលបានរៀបរាប់ជូនខាងលើទេ។

| ភាគី | កាលបរិច្ឆេទ | ឈ្មោះមេធាវី | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|---|
| សហមេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ | ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ | ផាត់ ពៅស៊ាង<br>Diana ELLIS, QC | ភ្នំពេញ | [signature] [stamp: AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA] |

---

[44] ដីកាដំណោះស្រាយ កថាខណ្ឌ១៥៦២។

[45] សារណាតបរបស់មេធាវីការពារក្តីទៅនឹងចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីអៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១០ ឯកសារលេខ D427/2/11។